Ottawa County Health Department

# សន្លឹកព័ត៌មានសាធារណៈ

## រោគរបេង [TB/TUBERCULOSIS]

**តើរោគរបេងគឺជាអ្វី?**

របេងគឺជាជម្ងឺឆ្លងមួយ បង្កដោយបាក់តេរីមួយ ។ វាពាក់ព័ន្ធសួត ប៉ុន្តែវាអាចពាក់ព័ន្ធនឹងសរីរាង្គដទៃទៀតបានដែរ ។

**តើរោគរបេងត្រូវបានឆ្លងតាមរបៀបអ្វីខ្លះ?**

របេងអាចឆ្លងបាន តាមរបៀបទាំងឡាយខាងក្រោមនេះ:

- អ្នកមានជម្ងឺរបេង **សកម្ម** អាចចម្លងជម្ងឺឱ្យអ្នកផ្សេងបាន តាមរយៈដំណក់ទឹកតូចល្អិតក្នុងខ្យល់មកពីការកណ្តាស់ ឬការក្អក ។
- អ្នកមានជម្ងឺរបេង **អសកម្ម** មិនអាចចម្លងជម្ងឺឱ្យអ្នកផ្សេងបានទេ ហើយក៏គ្មានរោគសញ្ញាអ្វីដែរ ។

**តើអាចមានរោគសញ្ញាអ្វីខ្លះ?**

រោគសញ្ញាអាចមានរួមទាំង:

- ក្អក
- ក្តៅខ្លួន
- នឿយហត់
- បែកញើសពេលយប់
- ក្អកចេញឈាម
- ស្រក់ទំងន់ដោយគ្មានបំណង
- ហឺត
- ឈឺដើមទ្រូង
- ពិបាកដកដង្ហើម

**តើរោគរបេងត្រូវបានវិនិច្ឆ័យរោគយ៉ាងដូចម្តេច?**

ការពិនិត្យមានរួមទាំងការថតដើមទ្រូងដោយកម្មរស្មីអិក្ស និងការពិនិត្យស្លេស្ម ។

**តើរបេងត្រូវបានព្យាបាលយ៉ាងដូចម្តេច?**

ជម្ងឺរបេង សកម្ម ត្រូវបានព្យាបាលដោយថ្នាំប៉ុន្មានមុខជាមួយគ្នា ។ ធម្មតា ការព្យាបាលមានរយៈពេល 6 ខែ ឬយូរជាង ។ អ្នកមានជម្ងឺរបេងត្រូវតែនៅដាច់ដោយឡែកពីអ្នកផ្សេង រហូតដល់ជាទាំងស្រុង ។

ជម្ងឺរបេង អសកម្ម ត្រូវបានព្យាបាលរយៈពេលប្រាំបួនខែ ដោយថ្នាំអង់ទីប៊ីយ៉ូទិកមួយ ។ អ្នកភាគច្រើនដែលមានជម្ងឺរបេងអសកម្ម មិនកើតរបេងសកម្មទេ ជាពិសេស បើគេផឹកថ្នាំអស់រយៈពេលប្រាំបួនខែ ។

**តើខ្ញុំអាចបង្ការជម្ងឺរបេងយ៉ាងដូចម្តេច?**

របេងអាចបង្ការបាន ។ មនុស្សដូចជា អ្នកធ្វើការខាងវិស័យពេទ្យ ហើយអ្នកដែលមានបញ្ហាសុខភាពរ៉ាំរ៉ៃមួយចំនួន នោះគួរតែធ្វើតេស្តរបេងស្បែក ។ បើតេស្តស្បែកបង្ហាញថាមានរបេង នោះជាការសំខាន់ដែលគេត្រូវមានការពិនិត្យ និងការព្យាបាលដ៏ត្រឹមត្រូវ ។ ការព្យាបាលរបេងឱ្យបានបន្ទាន់ អាចជួយទប់ស្កាត់នូវការរាលដាលនៃជម្ងឺ ។

**សម្រាប់ព័ត៌មានបន្ថែមទៀតអំពីជម្ងឺរបេង:**

Ottawa County Health Department
www.miOttawa.org

Center for Disease Control and Prevention
www.cdc.gov/nchstp/tb/faqs/pdfs/qa.pdf
ទូរស័ព្ទ: (888) 246-2675

Medline Plus/National Institutes of Health
www.nlm.nih.gov/medlineplus/ency/article/000077.htm

12251 James St., Suite 400
Holland, MI 49424

ទូរស័ព្ទ: (616) 396-5266
ទូរសារ: (616) 393-5643

វិបសាយ: www.miOttawa.org